ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ស្រែក្រសាំង

## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

30

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ស្រែក្រសាង |
| ភូមិ | ៖ | ស្រែក្រសាំង |
| ឃុំ | ៖ | ស្រែក្រសាំង |
| ស្រុក | ៖ | សៀមបូក |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ស្រែក្រសាំង រយៈពេល ៣ ឆ្នាំ( ២០២០ - ២០២២ )

សហគមន៍នេសាទ ៖ ស្រែក្រសាំង
ភូមិ ៖ ស្រែក្រសាំង
ឃុំ ៖ ស្រែក្រសាំង
ស្រុក ៖ សៀមបូក
ខេត្ត ៖ ស្ទឹងត្រែង

ខែមករា ឆ្នាំ២០១៩

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ........ ២

ក.ប្រជាពលរដ្ឋ ........ ២

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៣

ឃ.ធនធានជលផល ........ ៤

ឃ.១.ប្រភេទត្រី៖ ........ ៤

ឃ.២.ប្រភេទវារីសត្វ៖ ........ ៤

ឃ.៣.ប្រភេទសត្វបក្សី ........ ៤

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៥

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនវិស័យ ........ ៦

ខ. គោលបំណងរួម ........ ៦

គ.គោលបំណងជាក់លាក់ ........ ៦

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៦

ឃ.១.ធនធានជលផល និងអេកូឡូស៊ី ........ ៦

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៦

ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ........ ៧

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ៧

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៨

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៨

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ........ ៨

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ៩

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........ ១០

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ...................................................... ១០
ឃ.៣. ការងារគ្រប់គ្រង ........................................................................................................ ១០
ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........................................................ ១០
ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ......................................................... ១១
ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ............................................ ១១
ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............................................ ១១
ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ...................................................... ១២
ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ............................................................................ ១២
ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោមៈ ........................................... ១២
ច.យុទ្ធសាស្ត្រ ...................................................................................................................... ១៣
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ស្រែក្រសាំង រយៈពេល៣ឆ្នាំ** (**២០២០ ដល់ ២០២២**) ............................................................................................................ ១៤
**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ**(**២០២០- ២០២២**) ........................................................ ១៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទស្រែក្រសាំង ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ១៩៩៧ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រយៈពេល៣ឆ្នាំគឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទនេះ មានទីតាំងស្ថិតនៅក្នុងភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន៣៥០គ្រួសារ ស្មើនឹង៦៩០នាក់ ស្រីចំនួន៣០៧នាក់ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០៤នាក់។ សហគមន៍នេសាស្រែក្រសាំង ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទនេះ បានអនុវត្តសកម្មភាពសំខាន់ៗ មានដូចជា ការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ការរៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺៈ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន ការកាប់បំផ្លាញព្រៃលិចទឹកតាមដងអូរ នាំឱ្យបាត់បង់ព្រៃលិចទឹកជាច្រើន ត្រីថយចុះគ្រប់ប្រភេទ ការនេសាទនៅរដូវត្រីពងកូន បាក់ច្រាំងមាត់ទន្លេ និងកំណើនអ្នកនេសាទមកពីក្រៅ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត កំណើនប្រជាពលរដ្ឋ ខ្វះប្រភពទឹកធ្វើស្រែ ខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ តម្លៃផល ផលិតផលមិនស្ថេរភាព និងទីផ្សារនៅឆ្ងាយពីភូមិ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមាន ការប្រើឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់ ឧបករណ៍ឆក់ និងសារជាតិពុល) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន មិនសូវមានការលើកទឹកចិត្តដល់គណកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ស្តីពីជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

ក.ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងភូមិស្រែក្រសាំងសរុប ២.៤០៩នាក់ ស្រី១.៣៤១នាក់ ស្មើនឹងចំនួន៦១៩គ្រួសារ និងមាន ៦១១ ខ្នងផ្ទះ (បូករួមទាំងភូមិឧបសម្ព័ន្ធ) ចំនួនប្រជាពលរដ្ឋជាជនជាតិខ្មែរ១០០% ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ៨០% និងសាសនាអ៊ីស្លាម ២០%។

ប្រជាពលរដ្ឋក្នុងភូមិស្រែក្រសាំង មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន ៦៥ នាក់
- ចំនួនជនពិការមានប្រុស ១៤ នាក់ ស្រី ០៤ នាក់
- ចំនួនក្មេងកំព្រាមានចំនួន ០២នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន០០នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន២៤៧ នាក់ ស្រី១២៨ នាក់ កម្រិតអនុវិទ្យាល័យចំនួនសរុប១៥៧ នាក់ស្រី៨៣ នាក់ វិទ្យាល័យចំនួន ២២៣ នាក់ /ស្រី ១១១ នាក់។

ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន ២១០គ្រួសារ
- ធ្វើស្រែចំនួន ៥៨៥ គ្រួសារ ដែលមានទំហំដីចំនួនសរុប ២៥ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន ១៦៤ គ្រួសារ / ដែលមានទំហំ ១ ហិកតា
- ជាងផ្ទះចំនួន ១០ គ្រួសារ
- ធ្វើចំការចំនួន៣២ គ្រួសារ ដែលមានទំហំដីចំនួនសរុប ១៥ ហិកតា (ស្រូវ ដំឡូងមី ចន្ទី ....)
- លក់ដូរ ចំនួន៦៥ គ្រួសារ
- ប្រមូលទិញផលនេសាទ ៧ គ្រួសារ
- ជាងធ្វើទូក ២ នាក់
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ៨៥ ភាគរយ នៃគ្រួសារអ្នកភូមិ
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួនសរុប ១១០ គ្រួសារ (ធ្វើផ្អក ប្រហុក ត្រីប្រៃ ចាប់ពី១០-៦០គីឡូក្រាម)
- ពេទ្យសត្វ ១ នាក់ ។

## ៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក.ទីតាំង

កន្លែងនេសាទសហគមន៍ស្រែក្រសាំង ជាដែននេសាទសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ស្រែក្រសាំងមានទំហំ ៧០០ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

- ខាងជើងជាប់នឹង អូរក្រសាំងភូមិដំរីផុង ឃុំកោះសំពាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងត្បូងជាប់នឹង អូរកាំងក្របី ភូមិកោះព្រះ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងកើតជាប់នឹង ភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងលិចជាប់នឹង ភូមិកោះក្រូច ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ។

ខ.ដែននេសាទ

កន្លែងសហគមន៍នេសាទស្រែក្រសាំង មានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានអូរចំនួន៩ និងអន្លង់ចំនួន២។

ខ.១.ទន្លេមេគង្គ

| ឈ្មោះទន្លេ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៩.០០០ | ពេញមួយឆ្នាំ |

ខ.២.អូរ

| ឈ្មោះអូរ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| អូរប្រកាប់ | ២.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរតូច | ៥០០ | នេសាទបានក្នុងរដូវវស្សា |
| អូរកាន់លឿង | ១.៥០០ | នេសាទបានក្នុងរដូវវស្សា |
| អូរតាផន | ៣០០ | នេសាទបានក្នុងរដូវវស្សា |
| អូរបាញ់ខ្លា | ៥.០០០ | នេសាទបានវស្សានិងប្រាំង |
| អូរតាមឿ | ២០០ | នេសាទបានក្នុងរដូវវស្សា |
| អូរតាឃី | ៣០០ | នេសាទបានក្នុងរដូវវស្សា |
| អូរតាមុត | ១៥០ | នេសាទបានក្នុងរដូវវស្សា |
| អូរក្រសាំង | ១.២០០ | នេសាទបានវស្សានិងប្រាំង |

ខ.៣.អន្លង់

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់កាំងក្រសាំង | ១៥០ x ៣០០ | ៤៥.០០០ | ២០ | ១៥ |
| អន្លង់ក្រហម | ៥០ x ៥០០ | ២៥.០០០ | ១៣ | ៨ |

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន០១អន្លង់ គឺអន្លង់កាំងក្រសាំង តាមការសម្រេចរបស់មហាសន្និបាត។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់កាំងក្រសាំង | ១៥០ x ៣០០ | ៤៥.០០០ | ២០ | ១៥ |

ឃ.ធនធានជលផល

ឃ.១.ប្រភេទត្រី

ត្រីរស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ឆ្លូញ ខ្មាន់ ឆ្ពិន ច្រកែង កន្ទ្រប់ ត្រីដំរី កាហែរ ត្រីលិញ ត្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឬស្សី ត្រីខ្ទឹង ត្រីខ្សា ត្រីកេះ ឆ្តោក ត្រីកែ ត្រីត្រសក់ ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីក្របី ត្រីឬស្សីចេក ត្រីក្អុក ត្រីគ្រំ ត្រីកំបុកច្រមុះ ត្រីខ្សាថ្ម ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអន្លង ត្រីអាចម៍កុក...។

ឃ.២.ប្រភេទវារីសត្វ៖

ក្តាម ខ្យង់ ខ្ចៅ គ្រុម លៀស អណ្តើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ីង គីង្គក់...។

ឃ.៣.ប្រភេទបក្សី៖

កុកស កុកក្រក មាន់ទឹក មាន់ ប្រវឹក ទាព្រៃ រនាលខ្យង ក្រសារ ក្អែកទឹក ក្អែកគោក...។

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖

ដើមត្រែង ដើមអញ្ចែង ដើមរំចេក ដើមអណ្តែង ដើមរាំង ដើមល្វា ដើមផ្កាទឹក ដើមព្រុះទឹក ដើមបន្លាឃ្លេ...។

## ៤.ការធ្វើនេសាទ

ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៩៦នាក់ ស្ត្រី១០២នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទមានចំនួន ៨៥នាក់ ស្ត្រី៣៥នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៦០នាក់ស្រី២៥នាក់

ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកការល្បាតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| សន្ទូចរនង | ផ្លែ | ២១០គ្រួសារ× ៥០ផ្លែ= ១.១០០ ផ្លែ | ៥០គ្រួសារ ×៥០ផ្លែ= ២.៥០០ផ្លែ | ១០គ្រួសារ × ៥០ផ្លែ= ៥០០ផ្លែ | ផ្លែលេខ១២ ដល់០៥ | ផ្លែលេខ១២ ដល់០៥ | ផ្លែលេខ១២ ដល់០៥ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ២១០គ្រួសារ x៣ =៦៣០វង់ | ៥០គ្រួសារ ×១វង់=៥០ | ១០គ្រួសារ x១ =១០វង់ | សំរុង៣,៥០ -៥,៥០ម | សំរុង៣,៥០ - ៥,៥០ម | សំរុង៣,៥០ - ៥,៥០ម | ពេញមួយឆ្នាំ |
| ចាន់ | គ្រឿង | ២០គ្រួសារ×៥ គ្រឿង=១០០ គ្រឿង | ៨គ្រួសារ× ២គ្រឿង= ១៦ គ្រឿង | គ្មាន | មុខកាត់៣,៥ ស.ម ប្រវែង ៨០ស.ម | មុខកាត់៣,៥ ស.ម ប្រវែង ៨០ស.ម | គ្មាន | ខែ៨-១០ |
| លប | គ្រឿង | ៤០គ្រួសារ x៥= ២០០គ្រឿង | ៨គ្រួសារ×២ =១៦គ្រឿង | គ្មាន | មុខកាត់១.២ ម ប្រវែង២ម | មុខកាត់១,២ ម ប្រវែង២ម | | ខែ៨-១០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទ្រូ | គ្រឿង | ២០គ្រួសា x៥ =១០០ គ្រឿង | ៨គ្រួសាx៣ =២៤គ្រឿង | គ្មាន | មុខកាត់០,៣ មប្រវែង១,២ ម៉ែត្រ | មុខកាត់៣០ ស.ម ប្រវែង ១,២ម | គ្មាន | ខែ៨-១០ |
| សៃយ៉ឺន | គ្រឿង | ៤០គ្រួសារx៥ =២០០ គ្រឿង | ៨គ្រួសារ× ២ គ្រឿង= ១៦ គ្រឿង | គ្មាន | មុខកាត់១,២ ម ប្រវែង ២,៥ម | មុខកាត់១,២ ម ប្រវែង ២,៥ម | គ្មាន | ខែ៨-១១ |
| តុំ | គ្រឿង | ១៥គ្រួសារx៥ =៧៥ គ្រឿង | គ្មាន | គ្មាន | ទំហំ០,៣- ០,៥មប្រវែង ១ម | គ្មាន | គ្មាន | ខែ៧-១១ |
| ច្បូក | គ្រឿង | ៤០គ្រួសារx២ =៨០គ្រឿង | ៤គ្រួសារx ១=៤គ្រឿង | គ្មាន | ទំហំផ្លែ០,៣ ប្រវែង១,៥ម | ទំហំផ្លែ០,៣ ប្រវែង១,៥ម | គ្មាន | ខែ៧-១១ |
| ស្នាង | គ្រឿង | ៥០គ្រួសារ× ៣០ =១.៥០០ គ្រឿង | គ្មាន | គ្មាន | ប្រវែង១,២ម | គ្មាន | គ្មាន | ខែ៧-១១ |
| មង | ត្បូង | ២១០គ្រួសារx ៤ត្បូង=៨៤០ ត្បូង | ៥០គ្រួសារ× ៤ត្បូង= ២០០ ត្បូង | ១០គ្រួសារ × ៥ត្បូង= ៥០ ត្បូង | ក្រឡា២,៥ស .ម-១៥ស.ម ជម្រៅ៣ម | ក្រឡា២,៥ ស.ម-១៥ ស.ម ជម្រៅ ៣ម | ក្រឡា២,៥ ស.ម-១៥ ស.ម ជម្រៅ៣ម | ខែ៧-១១ |

ប្រភេទកាណូត

| ប្រភេទទូកកាណូត | ចំនួន (គ្រឿង) | | | ចំណុះ (គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេរវជាប់ម៉ាស៊ីនហុងដា | ១៨ | ៨ | ១០ | ៣០០-៥០០ | ១០០-៣០០ | ៣០០-៥០០ | ៥-៥,៥-៦,៥-៨-១៣ | ៥,៥-៦-១៣ | ១៣ |
| ទូកអុំ ទូកចែវ | ៣២ | ០ | ០ | ១០០ | ០ | ០ | ០ | ០ | ០ |

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |
| សរុប | | | ១.៦៦១,០៥ |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទស្រែក្រសាំង មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ.គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនៈវិស័យខាងលើ សហគមន៍នេសាទមានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងរដូវជំឡើង ដាំព្រៃលិចទឹកឡើងវិញ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និង ធានាការបែងចែកផលប្រយោជនធនធានជលផលជូនប្រជាពលរដ្ឋ ខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១.ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទឧបករណ៍នៅក្នុងដែននេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ...ងទន្លេមេគង្គ ...ន្លែងនេសាទសហ...មន៍ស្រែក្រសាំង | នេសាទពេញ ១ឆ្នាំជាលក្ខណៈគ្រួសារ | សន្ទូចរនង | ផ្លែលេខ១២ ដល់ ០៥ | ៥០ផ្លែ/គ្រួសារ | |
| | | សំណាញ់ | សំរុង៣,៥០-៥,៥០ម | ៣វង់/គ្រួសារ | |
| | | ចាន់ | មុខកាត់៣.៥០ស.ម ប្រវែង ៨០ ស.ម | ៥គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់១,២ម ប្រវែង ២ម | ៥គ្រឿង/គ្រួសារ | |
| | | ទ្រូ | មុខកាត់៣០ ម ប្រវែង ១,២ ម | ៥គ្រឿង/គ្រួសារ | |
| | | សៃយ៉ឺន | មុខកាត់១,២០ ម ប្រវែង ២,៥ ម | ៥គ្រឿង/គ្រួសារ | |
| | | តុំ | ទំហំ ៣០ -៥០ ស.ម ប្រវែង១ ម | ៥គ្រឿង/គ្រួសារ | |
| | | ច្បូក | ទំហំផ្លែ ០.៣ ស.ម ប្រវែង ១,៥ ម | ២គ្រឿង/គ្រួសារ | |
| | | ស្ទូង | ប្រវែង ១,២ ម | ៣០គ្រឿង/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| -អួរប្រកាប់<br>-អួរតូច<br>-អួរកាន់លឿង<br>-អួរតាផន<br>-អួរបាញ់ខ្លា<br>-អួរតាមឿ<br>-អួរតាឃី<br>-អួរតាមុត<br>-អួរក្រសាំង | ខែ៨ - ខែ១១ | សន្ទូចរនង | ផ្លែលេខ១២ ដល់ ០៥ | ៥០ផ្លែ/គ្រួសារ | |
| | | សំណាញ់ | សំរុង៣,៥០-៥,៥០ម | ៣វង់/គ្រួសារ | |
| | | ចាន់ | មុខកាត់៣.៥០ស.ម ប្រវែង ៨០ ស.ម | ៥គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់១,២ម ប្រវែង ២ម | ៥គ្រឿង/គ្រួសារ | |
| | | ទ្រូ | មុខកាត់៣០ ម ប្រវែង ១,២ ម | ៥គ្រឿង/គ្រួសារ | |
| | | សៃយ៉ឺន | មុខកាត់១,២០ ម ប្រវែង ២,៥ ម | ៥គ្រឿង/គ្រួសារ | |
| | | តុំ | ទំហំ ៣០ -៥០ ស.ម ប្រវែង១ ម | ៥គ្រឿង/គ្រួសារ | |
| | | ច្បូក | ទំហំផ្លែ ០.៣ ស.ម ប្រវែង ១,៥ ម | ២គ្រឿង/គ្រួសារ | |
| | | ស្ទូង | ប្រវែង ១,២ ម | ៣០គ្រឿង/គ្រួសារ | |
| | | មង | មងក្រឡា២,៥ស.ម-១៥ ស.មជម្រៅ៣ម | ៤ ត្បូង/គ្រួសារ | |

### ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះដែន នេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ឆ្នាំចាប់ផ្តើម | ឆ្នាំបញ្ចប់ |
| កន្លែងនេសាទសហគមន៍ស្រែក្រសាំង | បង្គោលព្រំធ្វើពីស៊ីម៉ង់ត៍ចំនួន ៤ បង្គោល | -លាងសម្អាតបង្គោលព្រំ និងជំរះស្មៅជុំវិញបង្គោល<br>-ផ្សព្វផ្សាយជាសាធារណៈ | ៥០ | -គណៈកម្មការ<br>-សមាជិកស/ន | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូផែនទីធ្វើអំពីដែក ចំនួន២ | ផលិតផ្ទាំងប៉ាណូផែនទី | ៥០០ | គណកម្មការ | ២០២០ | ២០២០ |
| | ស្លាកអប់រំ ៣០ | ផលិតស្លាកនិងចុះបោះស្លាក | ១២០ | គណកម្មការ | ២០២០ | ២០២០ |

### ឃ.១.៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះ | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់កាំង ក្រសាំង | ៤,៥ ហិចតា | -ត្រីមេពូជ<br>-សត្វស្លាប<br>-ព្រៃលិចទឹក | -ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឲ្យបានទូលំទូលាយ<br>-បោះទង់សំគាល់ព្រំតំបន់អភិរក្សចំនួន ៤ បង្គោល<br>-ចុះល្បាតការពារជាប្រចាំ | ៤២០ | ១០/២០២០ | ០៩/២០២២ |

### ឃ.១.៤.ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ស្រែក្រសាំង | តាមមាត់ទន្លេ និងតាមមាត់អូរ តាមភូមិ | ព្រៃលិចទឹកចម្រុះ | -ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>-រៀបចំផែនការដាំព្រៃលិចទឹក<br>-ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក<br>-ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>-ចុះល្បាតការពារជាប្រចាំ | ៥០០ | ២០២០ | ២០២២ |

### ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំឡើងដូចខាងក្រោម

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ៣០ គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់<br>-អនុវត្តជាក់ស្តែង ធ្វើទ្រុង និងផ្តល់ពូជ<br>-ចុះតាមដាន និងត្រួតពិនិត្យ | ពូជក្នុងស្រុក | ៤.៥០០ | ២០២០ | ២០២២ |
| ៣០ គ្រួសារចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | -ប្រជុំផ្សព្វផ្សាយជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក<br>-រៀបចំធ្វើទ្រុង និងផ្តល់ពូជដាក់ចិញ្ចឹម<br>-ចុះតាមដាន និងត្រួតពិនិត្យការថែទាំ | កូនជ្រូកពូជ ៣០ ក្បាលពូជ | ៣.៧០០ | ២០២០ | ២០២២ |
| រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍នេសាទ | -ប្រជុំផ្សព្វផ្សាយពីគោលបំណងគម្រោង<br>-សិក្សាប៉ាន់ប្រមាណអ្នកប្រើប្រាស់<br>-ជ្រើសរើសគណៈកម្មការគ្រប់គ្រង<br>-បង្កើតគោលការប្រើប្រាស់<br>-បណ្តុះបណ្តាលបច្ចេកទេស<br>-រៀបចំប្រព័ន្ធទឹកស្អាត<br>-តាមដានត្រួតពិនិត្យ | | ២០.០០០ | ២០២០ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| ១៥ គ្រួសារដាំបន្លែតាមបច្ចេកទេសកសិកម្មវៃឆ្លាត | -ប្រជុំផ្សព្វផ្សាយជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ<br>-ផ្តល់គ្រាប់ពូជដាំបន្លែ<br>-ចុះតាមដាន និងត្រួតពិនិត្យការថែទាំ | គ្រាប់ពូជបន្លែ (ស្ពៃ ត្រប់ ត្រកួន ត្រសក់ សណ្តែកគួរ) | ១.៥០០ | ២០២០ | ២០២២ |
| បង្កើតក្រុមសន្សំប្រាក់ ១ក្រុម (មានសមាជិក ៣០នាក់) | -ប្រជុំផ្សព្វផ្សាយទស្សនៈក្រុមសន្សំ<br>-បោះឆ្នោតជ្រើសរើសគណៈកម្មការ<br>-រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>-បណ្តុះបណ្តាលគណៈកម្មការក្រុម<br>-កិច្ចប្រជុំបូកសរុបប្រាក់សន្សំប្រចាំខែ<br>-ផ្តល់ទុនគាំទ្រ<br>-ត្រួតពិនិត្យ និងតាមដានជាប្រចាំ | សមាជិកក្នុងសហគមន៍នេសាទ | ១.០០០ | ២០២០ | ២០២២ |
| រៀបចំកន្លែងកំសាន្តសហគមន៍នេសាទទេសចរណ៍ធម្មជាតិ | -ប្រជុំផ្សព្វផ្សាយទស្សនៈទាន និងសារៈប្រយោជន៍នៃការរៀបចំកន្លែងកំសាន្ត<br>-ចុះពិនិត្យទីតាំង និងរៀបចំ<br>-បោះឆ្នោតជ្រើសរើសគណៈកម្មការ<br>-រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>-រៀបចំកម្មវិធី និងសេវាកំសាន្ត<br>-កៀងគរមូលនិធិកាំទ្រ<br>-ត្រួតពិនិត្យ និងតាមដានជាប្រចាំ | | ១.៥០០ | ២០២០ | ២០២២ |

**ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណកូនត្រី | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះធម្មជាតិតាមបច្ចេកទេសចំនួន៥គ្រួសារ/ឆ្នាំ) | -ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>-រៀបចំស្រះ និងដាក់កូនត្រី<br>-បណ្តុះបណ្តាលបច្ចេកទេស<br>-ត្រួតពិនិត្យ និងធ្វើសំណាក | ៥ ស្រះ ទំហំ៥ម× ១០ ម | ១.៥០០កូនត្រី/គ្រួសារ | ៩.០០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់និងការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការ | ១០០ | ២០២០ | ២០២២ | |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | ៣០០ | ២០២០ | ២០២២ | |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | ២៥០ | ២០២០ | ២០២២ | |
| | ផ្តល់ធុងចំរោះទឹកចំនួន៥០ គ្រួសារ | ១.២០០ | ២០២០ | ២០២២ | |
| | ជួសជុលអណ្តូងទឹក២កន្លែង | ១.០០០ | ២០២០ | ២០២២ | |
| | ពង្រឹងក្រុមក្រុមទ្រង់ទ្រងទ្រទ្រង់គ្រោះមហន្តរាយភូមិ និងចងក្រងបណ្តាញក្រុមទ្រទ្រ់គ្រោះមហន្តរាយភូមិ | ១០០ | ២០២០ | ២០២២ | |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ | ១៥០ | ២០២០ | ២០២២ | |

### ឃ.៣.ការងារគ្រប់គ្រង

### ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | ៣ដង/១ខែ | ១.០៨០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/១ខែ | ៤.៥០០ | ២០២០ | ២០២២ |
| ទិញទូកស្នាច់ និងម៉ាស៊ីន (១៣សេះ) | ១ គ្រឿង | ១.២០០ | ២០២០ | ២០២២ |
| ប្រេងសម្រាប់ចុះល្បាត | ៥០លីត្រ/ខែ | ១.៨០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ | ១ កន្លែង | ៦០០ | ២០២០ | ២០២២ |

### ឃ.៣.២.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ត្រូវរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដង | ៣៤០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ១២ដង | ៣៤០ | | |
| បណ្ដុះបណ្ដាលការរៀបចំរបាយការណ៍ កំណត់ហេតុ | ១ដង | ២៥០ | | |
| បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា | ១ដង | ២៥០ | | |
| បណ្ដុះបណ្ដាលសរសេរគម្រោងសំណើរ | ១ដង | ២៥០ | | |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្តផ្លាស់ប្ដូរបទពិសោធន៍ | ១ដង | ១,០០០ | | |

### ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សាមជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយច្បាប់ស្ដីពីជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| យុទ្ធនាការផ្សព្វផ្សាយ ប្រមូលឧបករណ៍នេសាទខុសច្បាប់ និងដុតបំផ្លាញចោល | ១ដង/ឆ្នាំ | ១៥០ | ២០២០ | ២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣០០ | ២០២០ | ២០២២ | - គណៈកម្មាការ<br>- អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០០ | ២០២០ | ២០២២ | - គណៈកម្មាការ<br>- អាជ្ញាធរឃុំ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | ចុះប្រមូលប្រាក់សមាជិកភាព៥០០៛ | ២០២០ | ២០២០ | ៨៦,២៥ | |
| បដិភាគប្រចាំឆ្នាំពីសមាជិក | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំចំនួន ៣.០០០/គ្រួសារ នៃសមាជិកសរុប | ២០២០ | ២០២២ | ៧៨៧,៥០ | |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅចំនួនចំនួន៦០នាក់(១០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៤៥០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាចំនួន ៨៥ នាក់ (១០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៦៣៧,៥០ | |
| បដិភាគពីក្រុមសន្សំប្រាក់ | ភាគលាភពីក្រុមសន្សំប្រាក់ | ២០២០ | ២០២២ | ៩០ | |
| សរុបថវិកាដែលសហគមន៍មាន | | | | ២.០៤៩ | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនិងអំណោយពីសប្បុរសជន) | -បញ្ចូលផែនការអភិវឌ្ឍសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>-ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>-ទាក់ទងទៅមន្ទីរពាក់ព័ន្ធជុំវិញខេត្ត<br>-សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | ៥៨.១១១ | |
| សរុបការប៉ាន់ប្រមាណចំណាយសហគមន៍ | | | | ៦០.១៦០ | |

### ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ | ២០០ | ២០២០ | ២០២២ | -គណៈកម្មការ<br>-អាជ្ញាធរឃុំ |

ច.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ ។

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| យ.១.ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| យ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០០<br>១ដង×១០០×២លើក×៣ឆ្នាំ | សហគមន៍នេសាទ<br>រដ្ឋបាលជលផល<br>អង្គការដៃគូ | ២០២០ | ២០២២ | |
| យ.១.២.ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | សម្អាតបង្គោលព្រំធ្វើពីស៊ីម៉ងត៍ចំនួន៤បង្គោល | - បង្គោលព្រំចំនួន៤ដើម ត្រូវបានសម្អាត និងថែទាំបានល្អ<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៥០ | រដ្ឋបាលជលផល<br>អង្គការនានា<br>សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទី និងរូបភាពផ្សព្វផ្សាយចំនួន២ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍នេសាទ | ៥០០ | | ២០២០ | ២០២០ | |
| | ផលិតស្លាកអប់រំដាក់នៅក្នុងសហគមន៍ និងតាមដងទន្លេ | ស្លាកអប់រំចំនួន៣០ត្រូវបានផលិត និងបានបោះនៅសហគមន៍នេសាទ/តាមទន្លេ | ១២០ | | ២០២០ | ២០២០ | |
| យ.១.៣.ការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់កាំងក្រសាំង | - ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍កន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ស្លាកនៅតំបន់អភិរក្ស៣០<br>- ចុះល្បាតការពារជាប្រចាំ | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍នេសាទ<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់កន្លែងអភិរក្ស | ៤២០ | រដ្ឋបាលជលផល<br>អង្គការនានា<br>សប្បុរសជន | ២០២០ | ២០២២ | |
| យ.១.៤.ផែនការ | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពី | ព្រៃលិចទឹកកើនឡើងវិញ | ៥០០ | រដ្ឋបាលជលផល | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ្រប់គ្រងការពារព្រៃលិចទឹក | សារៈប្រយោជន៍ព្រៃលិចទឹក<br>- រៀបចំផែនការដាំព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ធនធានត្រីមានការកើនឡើងវិញ | | អង្គការនានា សប្បុរសជន | | | |
| យ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| យ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់ ចំនួន៣០ គ្រួសារ | ៤.៥០០ | រដ្ឋបាលជលផល អង្គការដៃគូ | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូកចំនួន៣០ គ្រួសារ | ៣.៧០០ | | ២០២០ | ២០២២ | |
| | រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍នេសាទ | សហគមន៍មានប្រព័ន្ធទឹក១កន្លែង | ២០.០០០ | | ២០២០ | ២០២២ | |
| | ដាំបន្លែតាមបច្ចេកទេកកសិកម្មវ៉យឆ្លាត | មានគ្រួសារដាំបន្លែចំនួន៣០ គ្រួសារ | ១.៥០០ | | ២០២០ | ២០២២ | |
| | បង្កើតក្រុមសន្សំប្រាក់ | មានសមាជិកចូលរួមចំនួន១៥នាក់ | ១.០០០ | | ២០២០ | ២០២២ | |
| | រៀបចំកន្លែងកំសាន្តសហគមន៍ធម្មជាតិ១កន្លែង | សហគមន៍បានរៀបចំកន្លែងកំសាន្ត ដើម្បីរកចំណូលចូលសហគមន៍នេសាទ | ១.៥០០ | | ២០២០ | ២០២២ | |
| យ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងចំនួន៥ គ្រួសារ | ៩.០០០ | រដ្ឋបាលជលផល អង្គការនានា | ២០២០ | ២០២២ | |
| យ.២.៣.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាស | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការ | គណៈកម្មការ និងសមាជិកមានការយល់ដឹងពីផលប៉ះពាល់ពីការប្រែប្រួលអាកាស ធាតុ និងរបៀបបង្ការ | ១០០ | រដ្ឋបាលជលផល អង្គការនានា សប្បុរសជន | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ធាតុ | រៀបចំបង្គោលវាស់កម្ពស់ទឹក | មានបង្គោលវាស់កំពស់ទឹកចំនួន១ | ២០០ | | ២០២០ | ២០២២ | |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | មានកន្លែងទីទួលសុវត្ថភាពចំនួន១ | ១០០ | | ២០២០ | ២០២២ | |
| | ជួសជុលអណ្តូងទឹក | មានអណ្តូងស្នប់ ២អណ្តូង | ១.០០០ | | ២០២០ | ២០២២ | |
| | ផ្តល់ធុងចម្រោះទឹកដល់សមាជិក | មានធុងចម្រោះចំនួន៥០ធុង | ១.២០០ | | ២០២០ | ២០២២ | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ និងចងក្រងជាបណ្តាញ | មានចងក្រងជាបណ្តាញ | ១០០ | | ២០២០ | ២០២២ | |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការ ប្រែប្រួលអាកាសធាតុ | គណៈកម្មការមានចំណេះដឹងទាក់ទងនិងការបន្សាំការប្រែប្រួលអាកាសធាតុ | ២០០ | | ២០២០ | ២០២២ | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | បានចុះល្បាត៣ដង/ខែ | ១.០៨០ | រដ្ឋបាលជលផល អង្គការនានា សប្បុរសជន | ២០២០ | ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | បានចុះល្បាត២ដង/១ខែសហការជាមួយអាជ្ញាធរមូលដ្ឋាន | ៤.៥០០ | | ២០២០ | ២០២២ | |
| | ទិញទូកស្នាច់ម៉ាស៊ីន (១៣សេះ) | មានទូកម៉ាស៊ីន ចំនួន១គ្រឿង | ១.២០០ | | ២០២០ | ២០២២ | |
| | ប្រេងសម្រាប់ចុះល្បាត | ៥០លីត្រ/១ខែ | ១.៨០០ | | ២០២០ | ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍នេសាទ | មានស្នាក់ការ១ខ្នងសម្រាប់សហគមន៍ នេសាទធ្វើការងារ | ៦០០ | | ២០២០ | ២០២២ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ១ដង/១ខែ ជាមួយគណៈកម្មការ សមាជិកក្នុងសហគមន៍នេសាទ | ៣៤០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ចូលរួម១ដង/១ខែជាមួយក្រុមប្រឹក្សាឃុំ | ៣៤០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | -មានវគ្គបណ្តុះបណ្តាលលើមុខជំនាញនីមួយៗ ១លើក/១ឆ្នាំ | ២៥០ | | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | -សមត្ថភាពសហគមន៍នេសាទបានល្អ | ២៥០ | | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលការសរសេរគម្រោងសំណើ | គណៈកម្មការអាចអនុវត្តន៍បាន | ២៥០ | | ២០២០ | ២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | គណៈកម្មការទទួលបាននូវចំនេះដឹង និងបទពិសោធន៍ល្អ | ១.០០០ | | ២០២០ | ២០២២ | |
| ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀង | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផលច្បាប់និងបទដ្ឋាន បច្ចេកទេសពាក់ព័ន្ធ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយ ប្រមូលឧបករណ៍នេសាទខុសច្បាប់ និងដុតបំផ្លាញចោល | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ១៥០ | | ២០២០ | ២០២២ | |
| ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | -បានផ្សព្វផ្សាយ ២ដង/ឆ្នាំ<br>-បានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់សហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.៥.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | ភាគទានពីសមាជិកភាព | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព ៥០០៛ /នាក់ | ៨៦.២៥ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២០ | |
| | ភាគទានពីសមាជិកប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ១ឆ្នាំម្តង ៣,០០០៛/គ្រួសារ | ៧៨៧.៥ | | ២០២០ | ២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមកពីខាងក្រៅ១០,០០០/ទូក/ថ្ងៃ | ៤៥០ | | ២០២០ | ២០២២ | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ | ៦៣៧.៥ | | ២០២០ | ២០២២ | |
| | បដិភាគពីក្រុមសន្សំប្រាក់ | សហគមន៍នេសាទទទួលបានភាគលាភ ពីក្រុមសន្សំប្រាក់ជារៀងរាល់ចុងឆ្នាំ | ៩០ | | ២០២០ | ២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | | | ២០២០ | ២០២២ | |
| ង.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | -បានប្រជុំមហាសន្និបាត ១ដង/ឆ្នាំ<br>-ធ្វើសេចក្តីរាយការណ៍ពីលទ្ធផលការងារ និងលើកផែនការបន្ត | ២០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | × | | | | | | × | | | | | × | | | | | | | × | | | | | × | | | | | | | × | | | | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សម្អាតបង្គោលព្រំសហគមន៍នេសាទ | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ នេសាទចំនួន ២ផ្ទាំង | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ស្លាកអប់រំដាក់នៅសហគមន៍នេសាទ | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៣.ផែនការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់កាំងក្រសាំង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីកន្លែងអភិរក្ស និង សារៈប្រយោជន៍ | | | | | | | × | | | | | | | × | | | | | | | × | | | | | | × | | | | | | × | | | |
| ដាក់ទង់សម្គាល់កន្លែងអភិរក្ស និងដាក់ស្លាកសញ្ញា | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ឃ.១.៤. ផែនការគ្រប់គ្រង ការពារព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយអោយបានទូលំទូលាយពីសារៈប្រយោជន៍ | | | | | × | | | | | | | | × | | | | | | × | | | | | | × | | | | | × | | | | | | |
| រៀបចំផែនការដាំព្រៃលិចទឹក | | | | × | × | × | | | | | | | | | | | | | | | | | × | × | × | | | | | | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹកចំនួន២០ស្លាក | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | × | × | | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | | | | × | × | | | | | | | | | | | | × | × | | | | | | | | | | |
| រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍ | | | | | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | |
| ដាំបន្លែតាមបច្ចេកទេសកសិកម្មវ៉យឆ្លាត | | | | | | | | | | × | × | × | × | | | | | | | | | | | × | × | × | × | | | | | | | | × | × |
| បង្កើតក្រុមសន្សំប្រាក់១ក្រុម | | | | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| រៀបចំកន្លែងកំសាន្តទេសចរណ៍ធម្មជាតិលក្ខណៈសហគមន៍នេសាទ | | | | | | | | | | | | | | | | | × | × | × | × | × | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះលក្ខណៈគ្រួសារ | | | | | | | | × | × | × | × | × | | | | | | | | × | × | × | × | × | × | | | | | | × | × | × | × | × | |
| **ឃ.២.៣.ផែនការបង្ការ និងបន្សុំាការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សាងសង់អណ្តូងស្នប់ | | | | | | | | | | | | | | | | × | × | × | | | | | | | | | | × | × | × | | | | | | |
| ផ្តល់ធុងចម្រោះទឹក១០០ធុង | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | |
| ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការផ្សេងៗ | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំបង្គោលវាស់កម្ពស់ទឹក | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| កំណត់រៀបចំទីទួលសុវត្ថិភាព | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| ពង្រឹងគណៈកម្មការគ្រប់គ្រងគ្រោះមហន្ត រាយនៅក្នុងភូមិ និងចងក្រងបណ្តាញ | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សុំាការ ប្រែប្រួលអាកាសធាតុ | | | | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចុះល្បាតដោយសហការជា | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| មួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្ទាច់ម៉ាស៊ីន | | | × | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ | | | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បណ្តុះបណ្តាលពីការរៀបចំកំណត់ហេតុ របាយការណ៍ | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | | | | | | | | | | × | | | | | | | | | | | | | | × | | | | | | | × | | | | | |
| បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើរ | | | | | | | | | | | | | | | | | | | | | | | | | | × | | | | | | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងសហគមន៍នេសាទ | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | | × | | | |
| ផ្សព្វផ្សាយច្បាប់ជលផលនិងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយ ចុះប្រមូលឧបករណ៍នេសាទខុសច្បាប់ ដុតបំផ្លាញចោល | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន សន្និបាតប្រចាំឆ្នាំ | | | × | | | | | | | | | × | | | | | | | | | × | | | | | | | | × | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | | | | | | | × | × | × | | | | | | | | | | | × | × | × | | | | | | | | | × | × | × |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ភាគទានប្រចាំឆ្នាំ | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | |
| ប្រាក់បដិភាគអ្នកនេសាទខាងក្រៅ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ប្រាក់បដិភាគអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| បដិភាគពីក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាលនិងពីសប្បុរសជន) | | | | × | | | | | | | | | | | × | | | | | | | × | | | | | | | | × | | | | | | |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | |

លេខ........42 [illegible]........
បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង,ថ្ងៃទី...០៥...ខែ...[illegible]......ឆ្នាំ២០១៩
ជ.នាយផ្នែករដ្ឋបាលជលផលថាឡាបរីវ៉ាត់

លេខ......471/19
បានឃើញ និងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលថាឡាបរីវ៉ាត់
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ[illegible]...៨...ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្រែក្រសាំង,ថ្ងៃទី...21...ខែ......10......ឆ្នាំ២០១៩
មេឃុំស្រែក្រសាំង

អ៊ាង សំអួន

សូមគោរពជូន
លោកមេឃុំស្រែក្រសាំង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ[illegible]...៨...ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ភូមិស្រែក្រសាំង,ថ្ងៃទី...21......ខែ......10.......ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទស្រែក្រសាំង

លេខ..................

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ..............................ខែ..........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ស្ទឹងត្រែង,ថ្ងៃទី..........ខែ..........ឆ្នាំ២០១៩

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង**

**ល្បៀង_សេន**

លេខ..................

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

"ដើម្បីពិនិត្យ និងសម្រួល"

ថ្ងៃ..............................ខែ..........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ស្ទឹងត្រែង,ថ្ងៃទី..........ខែ..........ឆ្នាំ២០១៩

**នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង**

**ទុំ នីរ៉ូ**

លេខ..................

បានឃើញ និងឯកភាព

ថ្ងៃ..............................ខែ..........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី..........ខែ..........ឆ្នាំ២០២០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**